ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១១០

ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩

សាលដីកា

លេខ ៧៧ "III"

ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រមរបាយការណ៍

៥-លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ១១៤ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សើហ្វីរីន ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ២៧ "ក្រI.សវ" ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] សើហ្វីរីន ហៅ ឡោះ សាតីរីន ភេទប្រុស កើតឆ្នាំ១៩៧២ ជនជាតិខ្មែរឥស្លាម ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ មុខរបរយាមចំការ មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០១នាក់ ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

Scanned with CamScanner

ជាប់ចោទពីបទ បរិហាកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ ។

-<u>**ដើមបណ្ដឹងរដ្ឋប្បវេណី**</u> ឈ្មោះ [redacted] ហាលីម ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិខ្មែរឥស្លាម សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] រាជធានីភ្នំពេញ មានទីលំនៅស្នាក់នៅផ្ទះ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០៦នាក់ ។

-លោក [redacted] សៀងលី ជាមេធាវីការពារសិទ្ធិ ។

<u>**អំពីអង្គហេតុ**</u>

កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ មានករណីបរិហាកេរ្តិ៍ជាសាធារណៈ មួយបានកើតឡើងប្រព្រឹត្តនៅរាជធានីភ្នំពេញ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សើហ្វីរីន ដែលជាម្ចាស់គណនីហ្វេសប៊ុកឈ្មោះ [redacted] SOEFIRIN ដោយបានសរសេរបង្ហោះក្នុងទំព័រហ្វេសបុករបស់ខ្លួនថា "លោក [redacted] ហាលីម ជាភូឈ្មួយទី ១ នៅម៉ាស្ជិត (អាល់ម៉ូការ៉ម) នៅ [redacted] រាជធានីភ្នំពេញ បានយកថវិកាសម្រាប់សាងសង់ម៉ាស្ជិត (អាល់ម៉ូការ៉ម) ទៅចែកគ្នា..." ដែលបានលើកឡើងនេះ គឺខុសពីការពិត ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ឈ្មោះ [redacted] ហាលីម ទើបឈ្មោះ [redacted] ហាលីម ដាក់ពាក្យបណ្ដឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញតែម្ដង ។

-បានឃើញ សាលក្រមលេខ ១៦២៤ "ណ" ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សើហ្វីរីន ភេទប្រុស អាយុ៤៥ឆ្នាំ ពិន័យជាប្រាក់ចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀល) ពីបទ បរិហាកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានី កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សើហ្វីរីន សងសំណងជំងឺចិត្តចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហាលីម បណ្ដឹងទាមទារលើសពីនេះបដិសេធចោល ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សើហ្វីរីន និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហាលីម បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ៥៤៨ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] សើហ្វីរីន ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១៦២៤ "ណ" ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ។

Scanned with CamScanner

-បានឃើញ សាលដីកាលេខ២៧ "ក្រI.សវ" ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៥៤៨ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] សើហ្ស៊ីរីន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៦២៤ "ណ" ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

សាលដីកានេះជំនុំជម្រះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ១១៤ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ២៧ "ក្រI.សវ" ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទពិតជាបានសារភាពថាពិតជាខ្លួនបានបង្ហោះសារហ្វេសប៊ុកថាឈ្មោះ [redacted] ហាលីម បានយកថវិកាសង់វិហារទៅចែកគ្នាហើយសូមឱ្យថ្នាក់ដឹកនាំខ្មែរឥស្លាម និងក្រសួងពាក់ព័ន្ធជួយដោះស្រាយបញ្ហានេះផង ។ ការដែលជនជាប់ចោទសរសេរដូច្នេះមិនមែនជាអំពើអះអាងបំភ្លើស ឬទំលាក់កំហុសទៅលើឈ្មោះ [redacted] ហាលីម នោះទេ គឺជនជាប់ចោទមានចេតនាឱ្យថ្នាក់លើជួយរកតម្លាភាពនៃការប្រើប្រាស់ថវិការតែប៉ុណ្ណោះ ហើយការសរសេរក្នុងហ្វេសប៊ុកខាងលើក៏មិនទាន់ជាការធ្វើឱ្យប៉ះពាល់ដល់កិត្តិយសជនរងគ្រោះនោះទេ តែផ្ទុយទៅវិញ គឺជាការលើកឡើងពីកង្វល់ក្នុងការកសាងសាសនារបស់ខ្លួន និងឱ្យថ្នាក់លើជួយដោះស្រាយតែប៉ុណ្ណោះ ។ ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំធ្វើការបដិសេធទៅលើ សាលដីកាព្រហ្មទណ្ឌលេខ ២៧ ក្រ.I. "ស.វ" ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ។

-ជនជាប់ចោទឈ្មោះ [redacted] សើហ្ស៊ីរីន ហៅ [redacted] សាគីរីន បានឆ្លើយថា ខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលដោយសារតែខ្លួនមិនសុខចិត្ត កាលពីឆ្នាំ២០១៥ ប្រជាជនដែលប្រើប្រាស់លក់ដីបឹងសហគមន៍ បឹងខំពងដើម្បីយកទៅចែកប្រជាជននិងមួយចំនួនសម្រាប់សាងសងអគារ នៅពេលដែលលក់ដីបាន៥៤000$ (ហាសិបបួនម៉ឺន) ដុល្លារអាមេរិក ដែលមានលោក [redacted] លីម ជាប្រធាន, លោក [redacted] ឡោះ ជាអនុប្រធាន, និង [redacted] យ៉ាប់គួប ជាព្រះចៅអធិការវត្ត (បានស្លាប់នៅពេលដែលសាលាឧទ្ធរណ៍បានជម្រះក្តីរួចហើយ) មានសមាជិកគណៈកម្មការ១៣រូបគ្រប់គ្រងថវិការសម្រាប់ចែកប្រជាជន៤៨000$ (សែសិបប្រាំបីម៉ឺនដុល្លារ) និង៦ម៉ឺនដុល្លារ



Scanned with CamScanner

សម្រាប់សាងសងព្រះវិហារថ្មី រួមទាំងអគារចាស់នៅភូមិព្រៃកលាំងគឺមានអាយុកាលជិត១០០ឆ្នាំហើយ ។ នៅពេលដែលបែងចែកលុយ៤៩០០០ (សែសិបប្រាំបួនម៉ឺនដុល្លារ) ជូនប្រជាជនដោយមិនប្រក្រតី រួចថវិការ៦ម៉ឺនសាងសងអគារថ្មី ដោយគាត់បានសាងសងមួយចំនួន និងមួយចំនួនទៀត១៦២៥០$ សម្រាប់បុកគ្រឹះសាងសងអគារថ្មីនោះ តែគាត់មិនបានសាងសងនោះទេ ដោយខ្លួនជាប្រជាជនចេះតែរងចាំមើលព្រោះខ្លួនជាអ្នកកាន់សាសនាដែរត្រូវការព្រះវិហារដើម្បីថ្វាយបង្គំព្រះ គោរពទៅព្រះអាឡោះ ។ រយៈពេល៦ខែ ទៅ៧ខែ និងមួយឆ្នាំនេះ [redacted] ហាលីម មិនបានសាងសងនោះទេ ប្រជាជនក៏បាននាំគ្នាសួរ ដោយឈ្មោះ [redacted] ហាលីម បានឆ្លើយថាយកថវិការទៅចែកភូមិអស់ហើយ ដូច្នេះរួមទាំងដាក់ឈ្មោះខ្លួនក៏យកលុយរួមទាំងរបស់ខ្លួនចំនួន៥០០ដុល្លារទាំងដែលខ្លួនមិនដឹងអ្វីសោះ ។ ខ្លួនក៏មិនសុខចិត្ត ក៏មានការប្តឹងទៅដល់សង្កាត់ ដោយលោកចៅសង្កាត់បានដោះស្រាយឱ្យលោក [redacted] ហាលីម ប្រមូលលុយមកវិញ ហើយសាងសងវិហារថ្មីទៅ តែលោក [redacted] ហាលីម មិនបានគោរពតាមពាក្យសន្យារហូតមកទល់ឥលូវ ។ ដូច្នេះក៏ខ្លួនបានបង្ហោះហ្វេសប៊ុកសុំអន្តរាគមន៍ទៅថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំខ្មែរឥស្លាមប្រចាំនៅភូមិឱ្យជួយអន្តរាគមន៍ ដើម្បីសាងសងព្រះវិហារថ្មីនោះ តែលោក [redacted] ហាលីម អត់រហូតមកដល់សព្វថ្ងៃនេះ ។ ជាក់ស្តែងដោយមានការប្រជុំ មានកំណត់ហេតុ ភស្តុតាង និងស្នាមមេដៃចែកលុយគ្នាផងដែរ។

-លោក [redacted] សៀងលី ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា ពាក់ព័ន្ធនឹងអង្គហេតុ ដូចមានក្នុងសារណាដាក់ក្នុងសំណុំរឿង គឺជនជាប់ចោទពិតជាបានសារភាពតាំងពីនៅសាលាដំបូងមក ហើយមានភស្តុតាងដែលបានបង្ហោះសារនៅលើហ្វេសប៊ុក ថាជនជាប់ចោទពិតជាបានបង្ហោះមែន ថែមទាំងបានបង្ហោះជាពីរ បីលើកទៀត ហើយខ្លឹមសារដែលបានបង្ហោះត្រង់ចំណុចស្នើសុំអន្តរាគមន៍ ។

<u>សំណូមពរ</u> សូមឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ ពិចារណា និងសម្រេចតម្កល់សាលក្រមរបស់សាលាដំបូង ក៏ដូចជាសាលដីការបស់សាលាឧទ្ធរណ៍ដែលបានសម្រេចទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ១១៤ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទ [redacted] សើហ្វីរីន ហៅ [redacted] សាគីរីន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា៤១៩ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ភ្នំពេញដែរ ដែលបានសម្រេចផ្តន្ទាទោសពិន័យជាប្រាក់ពីបទ បរិហាកេរ្តិ៍ជាសាធារណៈ និងបង្គាប់ឱ្យសងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីនោះ មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ព្រោះថា តាមរយៈសារទាំងពីរដែលជនជាប់ចោទបានបង្ហោះក្នុងហ្វេសប៊ុករបស់

Scanned with CamScanner

ខ្លួន ជនជាប់ចោទបានទទួលស្គាល់ថា ក្នុងទឹកប្រាក់សាងសង់ម៉ាស៊ិតចំនួន ៦០ ០០០ ដុល្លារចំណាយផ្សេងៗអស់ ៤៥ ៥៥០ ដុល្លារ ចំណែកថវិកា ១៤ ៤៥០ ដុល្លារ លោក [redacted] ហាលីម បានយកទៅចែកគ្នា និងថាខ្លួនមិនដែលបានទទួលប្រាក់ ៥០០ ដុល្លារក្នុងការបែងចែកនោះទេ ឃើញថា ការកំណត់នូវអង្គហេតុជាចំនួនទឹកប្រាក់ចំនួន ៦០ ០០០ ដុល្លារ ជាការអនុវត្តខុសច្បាប់ ។ ម្យ៉ាងទៀត តុលាការអង្គហេតុ មិនបានស្រាវជ្រាវ និងពិចារណាចំពោះទឹកប្រាក់ដែលមានការបែងចែកគ្នា ដូចមាននៅក្នុងកំណត់ហេតុស្ដីពីការប្រជុំគណៈកម្មការសហគម ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៥ និងបញ្ជីរាយឈ្មោះអ្នកដែលទទួលប្រាក់ចំនួន២៣នាក់ ដែលជាមូលដ្ឋានសំខាន់នៃការចោទប្រកាន់ពីបទល្មើសនេះ ឃើញថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ មានមូលហេតុត្រឹមត្រូវតាមការកំណត់នៃមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៧ ក្រ.I.សវ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះ មិនត្រឹមត្រូវតាមច្បាប់ទេ ។

**ហេតុដូច្នេះ**

**សម្រេច**

**១-ទទួល** បណ្ដឹងសាទុក្ខលេខ ១១៤ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទ [redacted] សើហ្វ៊ីរីន ហៅ [redacted] សាគីរីន ។

**២-បដិសេធ** សាលដីកាព្រហ្មទណ្ឌលេខ២៧ ក្រ.I.សវ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទាំងមូល ។

**៣-បង្គាប់ឱ្យបញ្ជូន** សំណុំរឿងព្រហ្មទណ្ឌលេខ១១០ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីស្រាវជ្រាវបន្ថែម និងជំនុំជម្រះជាថ្មី ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner